# មិនខ្លាចនឹងឈរតែម្នាក់ឯង

*ដោយប្រធាន ថូម៉ាស អេស ម៉នសុន*

បងប្អូនប្រុសជាទីស្រឡាញ់របស់ខ្ញុំ វាជាឱកាសមួយដ៏អស្ចារ្យដើម្បីនៅជាមួយនឹងអ្នកនារាត្រីនេះ ។ យើងជាអ្នកកាន់បព្វជិតភាពនៃព្រះបានបង្កើតនូវចំណង និងភាពជាបងប្អូនប្រុសមួយដ៏ធំ ។ យើងអាននៅក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញា កណ្ឌ 121 ខ 36 « ថាសិទ្ធិទាំងឡាយនៃបព្វជិត-ភាព គឺជាប់ជាមួយនឹងអំណាចទាំងឡាយនៃស្ថានសួគ៌ » ។ ឱ ! អំណោយដែលបានប្រទានមកឲ្យយើងមានភាពអស្ចារ្យអ្វីម្ល៉េះ ---ដើម្បីកាន់បព្វជិតភាពដែល « ជាប់ជាមួយនឹងអំណាចទាំងឡាយនៃស្ថានសួគ៌ » ។

តែអំណោយទានដ៏មានតម្លៃនេះ នាំមក មិនមែនតែជាមួយពរជ័យដ៏ពិសេសប៉ុណ្ណោះទេ តែក៏មាននូវទំនួលខុសត្រូវដ៏ធំផងដែរ ។ យើងត្រូវដឹកនាំជីវិតយើង ដែលធ្វើឲ្យយើងមានភាពស័ក្តិសមជារៀងរហូតចំពោះបព្វជិតភាពដែលយើងកាន់ ។ យើងរស់នៅក្នុងគ្រាមួយដែលយើងត្រូវបានហ៊ុំព័ទ្ធទៅដោយរឿងជាច្រើនដែលចង់អូសទាញយើង ឲ្យចូលទៅ ក្នុងផ្លូវដែលអាចនឹងនាំយើងទៅរកក្តីវិនាស ។ ដើម្បីចៀសវាងពីផ្លូវបែបនេះ វាតម្រូវឲ្យមានការប្ដេជ្ញាចិត្ត និងភាពក្លាហាន ។

ខ្ញុំនៅចាំពីគ្រាមួយ --- ហើយអ្នករាល់គ្នាមួយចំនួននៅទីនេះ នារាត្រីនេះក៏នៅចាំផងដែរ ---ដែលបទដ្ឋាននៃមនុស្សភាគច្រើនស្រដៀងគ្នានឹងបទដ្ឋានរបស់យើង ។ ការណ៍នេះលែងមានទៀតហើយ ។ ថ្មីៗនេះ ខ្ញុំបានអានអត្ថបទមួយក្នុងសារព័ត៌មាន *New York Times* ស្ដីពីការសិក្សាមួយ ដែលកើតមានក្នុងរដូវក្ដៅនាឆ្នាំ 2008 ។

មានអ្នកសង្គមវិជ្ជាដ៏ល្បីឈ្មោះម្នាក់មកពីសាកលវិទ្យាល័យ នូត្រេ ដាម  បានដឹកនាំក្រុមស្រាវជ្រាវមួយ ដោយធ្វើបទសម្ភាសន៍លម្អិតជាមួយនឹងមនុស្សពេញវ័យចំនួន 230 នាក់ក្នុងប្រទេសអាមេរិក ។ ខ្ញុំជឿថា យើងអាចសន្មត់ដោយមុតមាំថា លទ្ធផលនឹងមានភាពស្រដៀងគ្នានៅក្នុងផ្នែកជាច្រើនក្នុងពិភពលោកនេះ ។

ខ្ញុំសូមចែកចាយជាមួយអ្នកនូវផ្នែកមួយនៃអត្ថបទដ៏មានអត្ថប្រយោជន៍នេះ ៖ « ពួកអ្នកធ្វើបទសម្ភាសន៍បានសួរសំណួរលម្អិតជាច្រើនពី ត្រូវ និងខុសពីការខ្វល់ចិត្តខាងសីលធម៌ និងអត្ថន័យនៃជីវិត ។ ក្នុងចម្លើយដ៏រហោតរហូតជាច្រើន ... អ្នកឃើញយុវវ័យទាំងនោះ នឹករកនិយាយនូវអ្វីៗដែលសមហេតុផលចំពោះបញ្ហាទាំងនេះ ។ តែពួកគេគ្មានគំនិត ឬពាក្យដើម្បីធ្វើដូច្នេះបានឡើយ ។ ពេលត្រូវបានសុំឲ្យរៀបរាប់ពីការខ្វល់ចិត្តខាងសីលធម៌ដែលពួកគេបានជួបប្រទះ ពីរភាគបីនៃយុវវ័យទាំងនោះ មិនអាចឆ្លើយនឹងសំនួរនោះ ឬមិនអាចរៀបរាប់ពីបញ្ហាអសីលធម៌បានឡើយ ដូចជា ថាតើពួកគេអាចមានលទ្ធភាពជួលផ្ទះឈ្នួលដ៏ជាក់លាក់មួយ ឬថាតើពួកគេមានប្រាក់គ្រប់គ្រាន់ ដើម្បីបង់ថ្លៃកន្លែងចតឡានរបស់ខ្លួនដែរទេ » ។

អត្ថបទនោះបានបន្តទៀតថា ៖ « ជំនឿដោយស្វ័យប្រវត្តិ ដែលពួកគេភាគច្រើនជឿម្តងហើយម្តងទៀត គឺថាជម្រើសខាងសីលធម៌ គឺគ្រាន់តែជាបញ្ហាមួយនៃការចូលចិត្តផ្ទាល់ខ្លួនប៉ុណ្ណោះ ។ ពួកគេបាននិយាយតាមធម្មតាថា ‹ វាជារឿងផ្ទាល់ខ្លួន វាអាស្រ័យលើបុគ្គលនោះ  តើខ្ញុំជានរណាទៅ ដែលត្រូវនិយាយរឿងទាំងនេះ ? › ដោយច្រានចោលនូវការគោរពចំពោះសិទ្ធិអំណាច មានយុវវ័យជាច្រើនបានភ្លាត់និយាយនូវពាក្យខ្លាំងៗផ្សេងទៀតថា ៖ ‹ ខ្ញុំនឹងធ្វើអ្វីដែលខ្ញុំគិតថាវាធ្វើឲ្យខ្ញុំរីករាយ ឬអារម្មណ៍ដែលខ្ញុំមានចំពោះវា ។ ខ្ញុំគ្មានផ្លូវធ្វើអ្វីផ្សេងឡើយ ក្រៅពីអារម្មណ៍ដែលខ្ញុំមាននៅខាងក្នុងខ្លួនប៉ុណ្ណោះ › » ។

ពួកអ្នកធ្វើបទសម្ភាសន៍ បានគូសបញ្ជាក់ថា ភាគច្រើននៃយុវវ័យទាំងនោះដែលពួកគេបានជួប « មិនបានទទួលធនធាននានា ---ពីសាលា ពីស្ថាប័ននានា ឬពីក្រុមគ្រួសារ ---ដើម្បីអភិវឌ្ឍភាពច្បាស់លាស់របស់ខ្លួនខាងសីលធម៌ឡើយ » ។[1]

បងប្អូនប្រុស ដែលមិនបានស្ដាប់ខ្ញុំនៅពេលនេះ អាចមានការសង្ស័យថាតើអ្វីទៅជាសីលធម៌ និងអសីធម៌ ឬអាចមានការសង្ស័យពីអ្វីដែលបានរំពឹងទុកចំពោះយើង ក្នុងនាមជាពួកអ្នកកាន់បព្វជិតភាពនៃព្រះ ។ យើងធ្លាប់ និងបន្តទទួលការបង្រៀនពីក្រឹត្យវិន័យរបស់ព្រះ ។ ថ្វីបើអ្នកអាចឃើញ ឬឮនៅកន្លែងផ្សេងក្ដី ក៏ក្រឹត្យវិន័យទាំងនេះ នឹងមិនផ្លាស់ប្ដូរឡើយ ។

ខណៈដែលយើងរស់នៅពីមួយថ្ងៃទៅមួយថ្ងៃ នោះក្ដីជំនឿរបស់យើងនឹងជួបនូវឧបសគ្គដែលស្ទើរតែចៀសមិនរួច ។ ពេលខ្លះ យើងអាចរកឃើញថាខ្លួនឯងហ៊ុំព័ទ្ធ ទៅដោយមនុស្សជាច្រើន ហើយយើងកំពុងឈរនៅខាងភាគតិច ឬអាចនឹងឈរតែម្នាក់ឯងចំពោះអ្វីដែលអាចទទួលបាន និងអ្វីដែលត្រូវបដិសេធ ។

តើយើងមានភាពក្លាហានដ៏ត្រឹមត្រូវដើម្បីឈរយ៉ាងរឹងមាំចំពោះជំនឿយើងដែរទេ ទោះជាយើងត្រូវឈរតែម្នាក់ឯងដោយការធ្វើដូច្នេះក្ដី ? ក្នុងនាមជាពួកអ្នកកាន់បព្វជិតភាពនៃព្រះ វាចាំបាច់ថា យើងអាចប្រឈមមុខ ---ដោយក្លាហាន ---នូវឧបសគ្គដែលយើងជួប ។

ពួកអ្នកល្បីឈ្មោះមួយចំនួន និងមនុស្សផ្សេងទៀតដែល ---បានគាំទ្រដោយសាធារណជន ---តាមហេតុផលមួយចំនួន ---មានការលំអៀងយ៉ាងខ្លាំងទៅរកការសើចចំអកដល់សាសនាជាទូទៅ ពេលខ្លះនៅក្នុងសាសនាចក្រ ។ បើទីបន្ទាល់យើងមិនបានចាក់ឫសឲ្យរឹងមាំល្អម នោះការរិះគន់បែបនេះអាចបណ្ដាលឲ្យយើងកើតមានការសង្ស័យចំពោះជំនឿយើងផ្ទាល់ ឬធ្វើឲ្យស្ទាក់ស្ទើរក្នុងការតាំងចិត្តរបស់យើង ។ ក្នុងការនិមិត្តរបស់លីហៃពីដើមជីវិតដែលមាននៅនីហ្វៃទី 1 ជំពូក 8 លីហៃបានឃើញមនុស្សកាន់តោងដំបងដែក រហូតដល់ពួកគេបានជឿនទៅមុខ ហើយទទួលទានផ្លែនៃដើមជីវិត ដែលយើងដឹងថា វាតំណាងឲ្យក្ដីស្រឡាញ់នៃព្រះ ។

ជាអកុសល បន្ទាប់ពីពួកគេបានទទួលទានផ្លែនោះមក មានមនុស្សមួយចំនួនបានខ្មាស់អៀន ពីព្រោះតែពួកអ្នកដែលនៅ « អគារដ៏ធំ ហើយទូលាយ » ដែលតំណាងឲ្យភាពឆ្មើងឆ្មៃនៃកូនចៅមនុស្ស ដែលកំពុងចង្អុលដៃខ្លួនទៅរកពួកគេ ហើយចំអកដាក់គេ ហើយពួកគេបានធ្លាក់តាមផ្លូវហាមឃាត់ទាំងឡាយ ហើយវង្វេងបាត់អស់ទៅ ។ ឱ ! ការចំអក និងការមើលងាយដែលជាឧបករណ៍មួយរបស់មាសត្រូវមានឥទ្ធិពលអ្វីម្ល៉េះ ! ជាថ្មីម្ដងទៀត បងប្អូនប្រុស តើយើងមានភាពក្លាហានដើម្បីឈរដោយរឹងមាំប្រឈមមុខនឹងការលំបាកបែបនេះដែរទេ ? បទពិសោធន៍ដំបូងរបស់ខ្ញុំ ខ្ញុំជឿលើការមានភាពក្លាហានជឿជាក់របស់ខ្ញុំ ដែលកើតមាន ពេលខ្ញុំបម្រើក្នុងទ័ពជើងទឹករបស់អាមេរិក នៅចុងសង្គ្រាមលោកលើកទី 2 ។

ការបំពាក់បំប៉នសម្រាប់ទ័ពជើងទឹកថ្មី ពុំមែនជាបទពិសោធន៍មួយដ៏ងាយស្រួលសម្រាប់ខ្ញុំ ឬសម្រាប់មនុស្សគ្រប់គ្នាដែលឆ្លងកាត់វាឡើយ ។ សម្រាប់បីសប្ដាហ៍ដំបូង ខ្ញុំបានធ្វើឲ្យជឿថា ជីវិតខ្ញុំគឺស្ថិតនៅក្នុងគ្រោះថ្នាក់ ។ ទ័ពជើងទឹកនេះ មិនមែនកំពុងព្យាយាមបំពាក់បំប៉នខ្ញុំទេ តែវាកំពុងព្យាយាមសម្លាប់ខ្ញុំហើយ ។

ខ្ញុំតែងចាំជានិច្ច ពេលថ្ងៃអាទិត្យបានមកដល់ បន្ទាប់ពីសប្ដាហ៍ដំបូង ។ យើងបានទទួលដំណឹងដ៏រីករាយមកពីមន្ត្រីតែងតាំងជាន់ខ្ពស់ម្នាក់ ។ ដោយឈរយ៉ាងម៉ឺងម៉ាត់នៅលើទីលានក្នុងខ្យល់ដ៏ត្រជាក់មួយនៃរដ្ឋ កាលីហ្វូញ៉ា យើងបានឮបញ្ជារបស់គាត់ថា ៖ « ថ្ងៃនេះ អ្នករាល់គ្នាទៅព្រះវិហារ ---អ្នករាល់គ្នាត្រូវទៅ លើកលែងតែខ្ញុំម្នាក់ប៉ុណ្ណោះ ។ ខ្ញុំត្រូវសម្រាក ! »

រួចហើយគាត់បានស្រែកថា « អ្នករាល់គ្នាដែលជា កាតូលិក អ្នកជួបក្នុងជំរំ ដេកាទើរ ---ហើយដល់ម៉ោងបីចាំត្រឡប់មកវិញ ។ បោះជំហានដើរទៅមុខ ! »  មានមនុស្សមួយក្រុមធំបានធ្វើតាមបញ្ជាគាត់ ។ រួចហើយគាត់ស្រែកបញ្ជាទៀតថា « អ្នកដែលមានសាសនាយូដា អ្នកជួបនៅ ជំរំហ៊ែនរី ---ហើយដល់ម៉ោងបីចាំត្រឡប់មកវិញ ។ បោះជំហានដើរទៅមុខ ! »

មានមនុស្សមួយក្រុមតូចបានធ្វើតាមបញ្ជាគាត់ ។ រួចហើយគាត់និយាយថា « អ្នកដែលជាពួកប្រូតេស្តង់ អ្នកជួបនៅសាលប្រជុំក្នុងជំរំ ហ្វារាហ្គាត់ ----ហើយដល់ម៉ោងបីចាំត្រឡប់មកវិញ ។ បោះជំហានដើរទៅមុខ ! »

រំពេចនោះស្រាប់តែមានគំនិតកើតឡើងចំពោះខ្ញុំថា « ម៉នសុន អ្នកមិនមែនជាកាតូលិក អ្នកមិនមែនជា យូដា អ្នកមិនមែនជាប្រូតេស្តង់ ។ អ្នកជាមរមនដូច្នេះអ្នកត្រូវឈរនៅទីនេះ! »  ខ្ញុំអាចអះអាងចំពោះអ្នកថា ខ្ញុំពិតជាមានអារម្មណ៍ឯកោមែន ។ ខ្ញុំពិតជាមានអារម្មណ៍ក្លាហាន និងការតាំងចិត្តមែន ---តែក៏មានភាពឯកោដែរ ។

រួចហើយ ខ្ញុំបានឮសម្លេងដ៏ផ្អែមល្ហែមបំផុតដែលខ្ញុំពុំធ្លាប់ឮមន្ត្រីតែងតាំងជាន់ខ្ពស់នោះនិយាយពីមុនឡើយ ។ គាត់បានមើលមកខ្ញុំ ហើយសួរថា « ចុះពួកអ្នកហៅខ្លួនឯងជាអ្វីទៅ ? » ខ្ញុំមិនបានដឹងថាមានមនុស្សផ្សេងទៀតកំពុងឈរពីក្រោយខ្ញុំលើទីលាននោះឡើយ រហូតដល់ពេលនោះ ។ យើងម្នាក់ៗបានឆ្លើយស្ទើរតែព្រមគ្នាថា « ពួកមរមន ! » វាពិបាកណាស់ ដើម្បីរៀបរាប់ពីក្ដីអំណរដែលមានក្នុងដួងចិត្តខ្ញុំ ពេលខ្ញុំក្រឡេកមើល ហើយឃើញពួកអ្នកបើកកប៉ាល់មួយក្រុមតូចផ្សេងទៀតនោះ ។ មន្ត្រីតែងតាំងជាន់ខ្ពស់រូបនោះ បានយកដៃអេះក្បាលក្នុងអារម្មណ៍នៃភាពច្របូកច្របល់ តែទីបំផុតបាននិយាយថា « ឥឡូវ ទៅរកកន្លែងមួយដើម្បីជួបគ្នាចុះ ។ ហើយដល់ម៉ោងបីចាំត្រឡប់មកវិញ ។ បោះជំហានដើរទៅមុខ ! »

លុះយើងដើរចេញ បានឆ្ងាយហើយ ខ្ញុំបានគិតពីពាក្យកំណាព្យមួយ ដែលខ្ញុំធ្លាប់រៀនក្នុងថ្នាក់កុមារកាលពីក្មេងថា ៖

*មិនខ្លាចធ្វើជាពួកមរមន*
*មិនខ្លាចនឹងឈរតែម្នាក់ឯង ។*
*មិនខ្លាចនឹងមានការតាំងចិត្តមួយដ៏រឹងមាំ*
*មិនខ្លាចនឹងប្រាប់ឲ្យគេដឹងឡើយ ។*

ទោះជាបទពិសោធន៍នោះ ចេញលទ្ធផលមកខុសពីអ្វីដែលខ្ញុំបានរំពឹងទុកក្ដី ក៏ខ្ញុំសុខចិត្តឈរម្នាក់ឯងដែរ បើវាចាំបាច់នោះ ។

ចាប់ពីថ្ងៃនោះមក មានពេលខ្លះ គ្មាននរណាម្នាក់ឈរពីក្រោយខ្ញុំឡើយ ដូច្នេះហើយខ្ញុំ *ត្រូវ* ឈរតែម្នាក់ឯង ។ ខ្ញុំមានអំណរអ្វីម្ល៉េះ ដែលខ្ញុំបានធ្វើការសម្រេចចិត្តជាយូរយារមក ដើម្បីបន្តរឹងមាំ ហើយស្មោះត្រង់ ដោយរៀបចំខ្លួនជាស្រេចដើម្បីការពារសាសនារបស់ខ្ញុំជានិច្ច បើវាចាំបាច់នោះ ។

ក្រែងលោ នៅគ្រាណាមួយ យើងមានអារម្មណ៍ខ្វះចន្លោះចំពោះកិច្ចការដែលមាននៅចំពោះមុខ បងប្អូនប្រុស ខ្ញុំសូមចែកចាយនឹងអ្នកនូវពាក្យពេចន៍មួយឃ្លាដែលនិយាយក្នុងឆ្នាំ 1987 ដោយប្រធានអែសរ៉ាថាហ្វបែនសឹន ដែលពេលនោះលោកជាប្រធាននៃសាសនាចក្រនេះ ខណៈដែលលោកបានថ្លែងទៅកាន់សមាជិកមួយក្រុមធំក្នុងរដ្ឋកាលីហ្វញ៉ា ។

លោកបានមានប្រសាសន៍ថា ៖ « ក្នុងគ្រប់សម័យកាល ពួកព្យាការីបានទន្ទឹងរង់ចាំនូវសម័យរបស់យើង ។ មានមនុស្សរាប់រយរាប់ពាន់លាននាក់ដែលបានស្លាប់ និងបានចាប់កំណើត បានចាំឃ្លាំមើលយើង ។ ពិតប្រាកដណាស់ ---អ្នកជាជំនាន់មួយដ៏ពិសេស ។ ជិត 6,000 ឆ្នាំហើយ ដែលព្រះបានរក្សាទុកអ្នកដើម្បីឲ្យអ្នកបង្ហាញខ្លួនក្នុងថ្ងៃចុងក្រោយ ពីមុនការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់ ។

មានមនុស្សមួយចំនួននឹងចាកចេញពីសាសនាចក្រនេះ តែនគរព្រះនឹងបន្តរង់ចាំការយាងមកវិញរបស់ម្ចាស់ខ្លួន ---ព្រះយេស៊ូវគ្រីស្ទ ។ ខណៈដែលជំនាន់នេះ មានក្ដីទុច្ចរិតដូចជាសម័យណូអា ពេលព្រះអម្ចាស់បានសម្អាតផែនដីនេះដោយទឹកជំនន់ក្ដី ក៏ពេលនេះមានភាពខុសគ្នាដ៏ធំមួយផងដែរ ។ គឺថា ព្រះបានរក្សាទុកគ្រាចុងក្រោយនេះ សម្រាប់កូនចៅដ៏រឹងមាំបំផុតរបស់ទ្រង់មួយចំនួន ដែលនឹងជួយលើកស្ទួយនគរនេះដោយជោគជ័យ » ។[3]

មែនហើយ បងប្អូនប្រុស យើងតំណាងឲ្យកូនចៅមួយចំនួនដ៏រឹងមាំបំផុតរបស់ទ្រង់ ។ ទំនួលខុសត្រូវរបស់យើង គឺដើម្បីធ្វើខ្លួនឲ្យស័ក្តិសមនឹងរាល់ពរជ័យដ៏រុងរឿង ដែលព្រះវរបិតាយើងគង់នៅស្ថានសួគ៌បានរៀបចំទុកឲ្យយើង ។ ទោះជាយើងទៅទីណា បព្វជិតភាពយើងនៅជាប់នឹងយើងជានិច្ច ។ តើយើងកំពុងតែឈរនៅក្នុងកន្លែងដ៏បរិសុទ្ធទាំងឡាយមែនទេ ?

ពីមុនអ្នកបណ្ដោយខ្លួន និងបព្វជិតភាពអ្នកឲ្យចូលក្នុងក្ដីអន្តរាយ ដោយចូលទៅកន្លែង ឬចូលរួមក្នុងសកម្មភាពដែលមិនសក្ដិសមចំពោះអ្នក ឬចំពោះបព្វជិតភាពនោះ សូមឈប់ រួចគិតពីផលវិបាករបស់វា ។ យើង ម្នាក់ៗត្រូវបានប្រគល់ឲ្យនូវបព្វជិតភាពអើរ៉ុន ។ ក្នុងដំណើរការនេះយើង ម្នាក់ៗ បានទទួលអំណាចដែលកាន់កូនសោសម្រាប់ការបម្រើរបស់ពួកទេវតា ។ ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី បានមានប្រសាសន៍ថា ៖ « អ្នកមិនអាចធ្វើកិច្ចការណាមួយ ដែលនឹងដាក់រនាំងរវាងអ្នក និងការបម្រើរបស់ពួកទេវតា សម្រាប់ប្រយោជន៍របស់អ្នកបានឡើយ ។

« អ្នកមិនអាចធ្វើជាមនុស្សអសីលធម៌តាមរូបភាពណាមួយបានឡើយ ។ អ្នកមិនអាចខ្វះភាពស្មោះត្រង់ ។ អ្នកមិនអាចបោកប្រាស់ ឬកុហក ។ អ្នកមិនអាចយកព្រះនាមនៃព្រះជាអាសារឥតការ ឬប្រើសម្ដីថោកទាប ហើយនៅតែមានសិទ្ធិ ដើម្បីទទួលបានការបម្រើពីពួកទេវតាបានឡើយ » ។[4]

បើក្នុងចំណោមអ្នករាល់គ្នាមាននរណាម្នាក់ បានធ្វើខុសនៅក្នុងជីវិត ខ្ញុំចង់ឲ្យអ្នកយល់ដោយគ្មានការងឿងឆ្ងល់អ្វីសោះថា មានផ្លូវត្រឡប់ថយក្រោយវិញ ។ ដំណើរការនោះ គឺហៅថា ការប្រែចិត្ត ។ ព្រះអង្គសង្គ្រោះយើងបានលះបង់ព្រះជន្មទ្រង់ ដើម្បីផ្ដល់ឲ្យអ្នក និងខ្ញុំនូវអំណោយទានដ៏វិសេសវិសាលនោះ ។ ថ្វីបើផ្លូវសម្រាប់ការប្រែចិត្ត មិនងាយស្រួលក៏ពិតមែន តែការសន្យានោះមានពិត ។ យើងត្រូវបានប្រាប់ថា « ទោះបើអំពើបាបរបស់ឯងដូចជាពណ៌ក្រហមទែងក៏ដោយ គង់តែនឹងបានសដូច ហិមៈ »[5] « ហើយ [ យើង ] នឹងលែងនឹកចាំពីអំពើបាបគេទៀតជាដរាបទៅ » ។[6]

ក្នុងចំណោមអ្នក ប្រហែលជាមានអ្នកដែលកំពុងគិតក្នុងចិត្តថា « មែនហើយ ខ្ញុំមិនបានរស់នៅតាមរាល់ព្រះបញ្ញត្តិ ហើយខ្ញុំមិនបានធ្វើនូវអ្វីដែលខ្ញុំគួរធ្វើឡើយ តែជីវិតខ្ញុំនៅតែមានភាពប្រសើរ ។ ខ្ញុំគិតថា ខ្ញុំអាចរីករាយនឹងជីវិត ហើយមិនចាំបាច់គោរពតាមព្រះបញ្ញត្តិឡើយ » ។ បងប្អូនប្រុស ខ្ញុំសូមសន្យានឹងអ្នកថា វានឹងមិនអាចកើតឡើងជារឿងរហូតនោះទេ ។

ប៉ុន្មានខែថ្មីៗនេះ ខ្ញុំបានទទួលសំបុត្រមួយពីបុរសម្នាក់ដែល មានគ្រាមួយបានគិតថា គាត់អាចធ្វើការណ៍ទាំងពីរយ៉ាងនេះបាន ។ ឥឡូវ គាត់បានប្រែចិត្ត ហើយបាននាំជីវិតគាត់ឲ្យមានការគោរពចំពោះគោលការណ៍ទាំងឡាយនៃដំណឹងល្អ និងព្រះបញ្ញត្តិ ។

ខ្ញុំចង់ចែកចាយនឹងអ្នកនូវកថាកណ្ឌមួយក្នុងសំបុត្រគាត់ ពីព្រោះវាតំណាងពីធាតុពិតនៃការគិតខុស ៖ « ខ្ញុំបានរៀនដោយខ្លួនឯង ( តាមរបៀបដ៏លំបាក ) ថា ព្រះអង្គសង្គ្រោះពិតជាមានបន្ទូលត្រឹមត្រូវមែន ពេលទ្រង់មានបន្ទូលថា ‹ គ្មាននរណាម្នាក់អាចនឹងបម្រើចៅហ្វាយពីនាក់បានទេ ត្បិតអ្នកនោះនឹងស្អប់មួយ ហើយស្រឡាញ់មួយ ឬស្មោះត្រង់នឹងមួយ ហើយមើលងាយមួយ អ្នករាល់គ្នាពុំអាចនឹងគោរពដល់ព្រះ និងទ្រព្យសម្បត្តិផងបានទេ › ។ [7] ខ្ញុំបានព្យាយាមយ៉ាងខ្លាំង ដើម្បីធ្វើរឿងទាំងពីរនោះ ។ ទីបំផុត ខ្ញុំមានតែភាពទទេរស្អាត ភាពងងឹត និងភាពឯកោ ដែលសាតាំងបានផ្តល់ដល់អស់អ្នកដែលជឿលើការបំភាន់ ការបញ្ឆោត និងការកុហករបស់វា » ។ [8]

ដើម្បីឲ្យយើងមានភាពរឹងមាំ និងស៊ូទ្រាំរាល់កម្លាំងដែលរុញច្រានយើងឲ្យចូលក្នុងផ្លូវខុស ឬរាល់សម្លេងដែលលើកទឹកចិត្តយើងឲ្យជ្រើសផ្លូវខុស នោះយើងត្រូវតែមានទីបន្ទាល់របស់យើងផ្ទាល់ ។ មិនថាអ្នកមានអាយុ 12 ឆ្នាំ ឬ 112 ឆ្នាំ ---ឬនៅក្នុងចន្លោះនោះទេ --- អ្នកអាចដឹងដោយខ្លួនឯងថា ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទពិត ។ សូមអានព្រះគម្ពីរមរមន ។ សូមពិចារណាពីការបង្រៀនរបស់វា ។

សូមទូលសួរព្រះវរបិតាសួគ៌ បើសិនជាវាពិត ។ យើងមាននូវការសន្យាថា « ហើយបើសិនជាអ្នករាល់គ្នា សូមសួរដោយចិត្តស្មោះស គឺដោយស្មោះអស់ពីចិត្ត ដោយមានសេចក្តីជំនឿជឿដល់ព្រះគ្រីស្ទ នោះទ្រង់នឹងសម្តែងសេចក្តីពិតនៃ ការណ៍នេះដល់អ្នក ដោយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ » ។ [9]

ពេលយើងដឹងថាព្រះគម្ពីរមរមនពិត នោះយើងក៏ដឹងដែរថា យ៉ូសែបស្ម៊ីធ  គឺពិតជាព្យាការី ហើយថាលោកបានឃើញព្រះជាព្រះវរបិតាដ៏អស់កល្ប និងព្រះរាជបុត្រាទ្រង់ ព្រះយេស៊ូវគ្រីស្ទ ។ យើងក៏ដឹងដែរថា ដំណឹងល្អត្រូវបានស្តារឡើងវិញក្នុងថ្ងៃចុងក្រោយនេះតាមរយៈយ៉ូសែប ស្ម៊ីធ ---រួមទាំងការស្តារឡើងវិញនៃបព្វជិតភាពអើរ៉ុន និងមិលគីស្សាដែកផងដែរ ។
ពេលយើងមានទីបន្ទាល់មួយ វាជាទំនួលខុសត្រូវរបស់យើងដើម្បីចែកទីបន្ទាល់នោះដល់អ្នកដទៃ ។ បងប្អូនប្រុស ភាគច្រើនអ្នករាល់គ្នាធ្លាប់បម្រើជាអ្នកផ្សាយសាសនានៅជុំវិញពិភពលោក ។ អ្នកដែលយុវជន ភាគច្រើននឹងធ្វើការបម្រើក្នុងពេលខាងមុខ ។ សូមរៀបចំខ្លួននៅពេលនេះសម្រាប់ឱកាសនោះ ។ សូមធ្វើឲ្យប្រាកដថា អ្នកមានភាពសក្តិសមដើម្បីបម្រើ ។

បើយើងបានរៀបចំខ្លួនដើម្បីចែកចាយដំណឹងល្អ នោះយើងនឹងត្រៀមខ្លួនជាស្រេចដើម្បីឆ្លើយតបនឹងពាក្យទូន្មាននៃសាវកពេត្រុស ដែលបានជម្រុញថា « ឲ្យប្រុងប្រៀបជានិច្ច ដោយសុភាព ហើយកោតខ្លាច ដើម្បីនឹងឆ្លើយតបដល់អ្នកណាដែលសួរពីហេតុនៃសេចក្តីសង្ឃឹមរបស់អ្នករាល់គ្នា » ។ [10]

យើងនឹងមានទំនួលខុសត្រូវក្នុងជីវិតយើងដើម្បីចែកចាយពីជំនឿយើង ទោះបីយើងមិនបានដឹងពីពេលដែលយើងនឹងត្រូវបានហៅឲ្យធ្វើដូច្នេះជានិច្ចក្តី ។ ឱកាសមួយបែបនេះបានកើតមានចំពោះខ្ញុំក្នុងឆ្នាំ 1957 ពេលខ្ញុំធ្វើការក្នុងអាជីពផ្នែកបោះពុម្ព ហើយត្រូវបានសុំឲ្យទៅទីក្រុងដាឡាស រដ្ឋតិចសា-ស ពេលខ្លះត្រូវបានគេហៅថា « ទីក្រុងដែលមានព្រះវិហារច្រើន » ដើម្បីនិយាយក្នុងការប្រជុំពិភាក្សាមួយសម្រាប់ពួកអ្នកជំនួញ ។

បន្ទាប់ពីបញ្ចប់ការនិយាយនោះ ខ្ញុំបានជិះឡានក្រុងតាមជាយក្រុងរបស់ទីក្រុងនោះ ។ ពេលយើងបានឆ្លងកាត់ព្រះវិហារមួយចំនួន អ្នកបើកឡានបាននិយាយថា « នៅខាងឆ្វេងដៃ អ្នកនឹងឃើញព្រះវិហារមេតូឌិស » ឬ « នៅខាងស្តាំគឺជាវិហារ កាតូលិក » ។

ពេលយើងឆ្លងកាត់អគារឥដ្ឋក្រហមដ៏ស្រស់ស្អាតមួយដែលសង់នៅលើភ្នំ អ្នកបើកឡានបាននិយាយថា « អគារនោះគឺជាកន្លែងដែលពួកមរមនជួបជុំគ្នា » ។ មានស្ត្រីម្នាក់បានស្រែកហៅថា « អ្នកបើកឡាន តើលោកអាចប្រាប់យើងនូវរឿងពីពួកមរមនបានទេ ? »

អ្នកបើកឡាននោះបានឈប់ឡានទៅជ្រុងផ្លូវម្ខាង ហើយបានងាកមកក្រោយ ដោយនិយាយថា « អ្នកស្រី អ្វីដែលខ្ញុំដឹងពីពួកមរមនគឺថាពួកគេជួបជុំគ្នានៅក្នុងអគារឥដ្ឋក្រហមនោះ ។ តើមាននរណាម្នាក់នៅលើឡាននេះដឹងរឿងពីពួកមរមនដែរទេ ? »

ខ្ញុំរង់ចាំមើលនរណាម្នាក់ឆ្លើយតប ។ ខ្ញុំបានក្រឡេកមើលទៅទឹកមុខរបស់មនុស្សម្នាក់ៗ ពីសញ្ញាថាស្គាល់ ហើយមានចង់ពន្យល់ខ្លះៗ ។ ខ្ញុំដឹងថាវាអាស្រ័យលើខ្ញុំដើម្បីធ្វើដូចដែលសាវកពេត្រុសបានឲ្យយោបល់ «ឲ្យប្រុងប្រៀបជានិច្ច ដោយសុភាព ហើយកោតខ្លាច ដើម្បីនឹងតបឆ្លើយដល់អ្នកណាដែលសួរពីហេតុនៃសេចក្ដីសង្ឃឹមរបស់អ្នករាល់គ្នា » ។ [11]

ខ្ញុំក៏ដឹងពីសេចក្ដីពិត ដែលបាននិយាយថា « នៅពេលការសម្រេចចិត្តមកដល់ នោះពេលវេលាសម្រាប់ការរៀបចំកន្លងផុតទៅ » ផងដែរ ។ អស់រយៈពេល 15 នាទីក្រោយមក ខ្ញុំមានឱកាសចែកចាយជាមួយនឹងអ្នកទាំងឡាយ នៅលើឡានក្រុងនូវទីបន្ទាល់របស់ខ្ញុំអំពីសាសនាចក្រ និង ជំនឿរបស់យើង ។ ខ្ញុំមានអំណរគុណចំពោះទីបន្ទាល់របស់ខ្ញុំ ហើយមានអំណរគុណដែលខ្ញុំបានរៀបចំខ្លួន ដើម្បីចែកចាយ ។

ខ្ញុំអធិស្ឋានដោយអស់ពីដួងចិត្ត និង ព្រលឹងខ្ញុំសុំឲ្យបុរសគ្រប់រូប ដែលកាន់បព្វជិតភាព នឹងគោរពបព្វជិតភាពនោះ ហើយស្មោះត្រង់ចំពោះទំនុកចិត្តពេលបព្វជិតភាពត្រូវបានផ្ដល់ឲ្យ ។ សូមឲ្យយើងម្នាក់ៗ ដែលកាន់បព្វជិតភាពនៃព្រះដឹងនូវអ្វីដែលគាត់ជឿ ។ សូមឲ្យយើងមានភាពក្លាហាន និង បានរៀបចំខ្លួន ដើម្បីឈរសម្រាប់អ្វីដែលយើងជឿ ហើយបើសិនជាយើងត្រូវឈរតែម្នាក់ឯងនៅក្នុងពេលនោះក្ដី សូមឲ្យយើងធ្វើដោយភាពក្លាហាន ទទួលកម្លាំងដោយចំណេះដឹងដែលជាភាពពិត គឺថា យើងពុំឈរតែឯងទេ នៅពេលយើងឈរជាមួយព្រះវរបិតាសួគ៌របស់យើង ។

នៅពេលយើងសញ្ជឹងគិតអំពីអំណោយទានមហិមា ដែលយើងបានទទួល --- « សិទ្ធិទាំងឡាយនៃបព្វជិតភាព គឺជាប់ជាមួយនឹងអំណាចទាំងឡាយនៃស្ថានសួគ៌ ដែលមិនអាចបំបែកបានឡើយ » --- សូមឲ្យការតាំងចិត្តរបស់យើង មានដើម្បីយាម និង ការពារបព្វជិតភាព ហើយមានភាពស័ក្តិសមចំពោះការសន្យាដ៏មហិមារបស់បព្វជិតភាព ។ សូមឲ្យយើងធ្វើតាមការណែនាំរបស់ព្រះអង្គសង្គ្រោះមកឲ្យយើង ដែលមាននៅក្នុងគម្ពីរនីហ្វៃទី 3 ៖ « ចូរលើកពន្លឺរបស់អ្នករាល់គ្នាឡើង ប្រយោជន៍ឲ្យបានភ្លឺដល់មនុស្សលោក ។ មើលចុះ យើងជាពន្លឺដែលអ្នករាល់គ្នានឹងលើកឡើង --- គឺនូវអ្វីៗដែលអ្នករាល់គ្នាបានឃើញយើងធ្វើ » ។ [12]

ដើម្បីឲ្យយើងធ្វើតាមពន្លឺនោះជានិច្ច ហើយលើកវាឡើងដើម្បីឲ្យពិភពលោកទាំងមូលមើលឃើញ នេះគឺជាការអធិស្ឋានរបស់ខ្ញុំ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. ដាវីឌ ប្រ៊ូក « If It Feels Right . . . ,» *New York Times* ថ្ងៃទី 12 ខែ កញ្ញា ឆ្នាំ 2011 ។
2. អាល់ប្រេហ្វត ឡត ថែននីសុន «Sir Galahad» stanza 1 បន្ទាត់ 3--4 ។
3. អែសរ៉ា ថាហ្វ បែនសឹន, « In His Steps » (Church Educational System fireside ថ្ងៃទី8 ខែ កុម្ភៈ ឆ្នាំ 1987) ។
4. Gordon B. Hinckley, « Personal Worthiness to Exercise the Priesthood,» *Liahona* ខែ កក្កដា ឆ្នាំ 2002 ទំព័រ 59; *Ensign* ខែ ឧសភា ឆ្នាំ 2002 ទំព័រ 52 ។
5. អេសាយ 1:18 ។
6. យេរេមា 31:34 ។
7. ម៉ាថាយ 6:24 ។
8. ក្នុង personal correspondence to President Thomas S. Monson ។
9. មរ៉ូណៃ 10:4 ។
10. ពេត្រុសទី1 3:15 ។
11. ពេត្រុសទី1 3:15 ។
12. នីហ្វៃទី3 18:24 ។